សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ:៦៤០/១៥-១១-២០០៤

សាលដីកា

លេខ:៤៣(ច)/២៨-៨-២០០៥

# នាមនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឱ្យប្រើ តាមក្រឹត្យលេខ:០៦ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណ:នៅសាលាឧទ្ធរណ៍ នាថ្ងៃទី២៨-៨-២០០៥ ដែលមានសមាសភាពដូចតទៅ :

### សមាសភាពក្រុមប្រឹក្សា

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

### តំណាងមហាអយ្យការ

លោក [redacted]

### ក្រឡាបញ្ជីសវនាការ

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ:៦៤០ ចុះថ្ងៃទី១៥-១១-២០០៤ រវាង :

១-ជនជាប់ចោទឈ្មោះ [redacted] **សៃ** ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិ [redacted]កបារាយណ៍ ខេត្តកំពង់ធំ ឪពុកឈ្មោះ [redacted] ស) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន០១នាក់ ទោសពីមុនមានជាប់ពន្ធនាគារ៥ឆ្នាំ ។ ឃុំខ្លួននៅពន្ធនាគារព្រៃសម១ ។

២-ជនជាប់ចោទឈ្មោ[redacted] **សន** ភេទប្រុស អាយុ៣៣ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិ [redacted] ខេត្តកំពង់ធំ ឪពុកឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន០១នាក់ ទោសពីមុនគ្មាន ។

៣-ជនជាប់ចោទឈ្មោះ [redacted] **ឈិន** ភេទប្រុស អាយុ៥៣ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិ [redacted] ស្រុកចំការលើ ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន០២នាក់ ទោសពីមុនគ្មាន. ។

៤-ជនជាប់ចោទឈ្មោះ [redacted] **ឆាន** ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ [redacted] ស្រុកបារាយណ៍ ខេត្តកំពង់ធំ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] រ) ប្រពន្ធឈ្មោះ [redacted] មាន កូន០៥នាក់ ទោសពីមុនគ្មាន ។/.

៥-ជនជាប់ចោទឈ្មោះ [redacted] **ហ៊ំន** ហៅ **គ្រឹម** ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ [redacted] ឃុំចើងបើង ស្រុកបារាយណ៍ ខេត្តកំពង់ធំ ឪពុកឈ្មោះ [redacted] ស) ម្តាយឈ្មោះ [redacted] ប្រពន្ធឈ្ម [redacted] មានកូន០២នាក់ ទោសពីមុនជាប់គុក១៥ឆ្នាំ ។

អ្នកទាំង៥ជាប់ចោទពីបទៈ អំពើភេរវកម្មប្លន់ ប្រព្រឹត្តនៅភូមិត្រពាំងឬស្សី ឃុំគីរធំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី១៧-៧-២០០១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា២ នៃច្បាប់ស្តីពីការផ្តន្ទាទោសអំពើភេរវកម្ម និង មាត្រា៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

មេធាវីការពារឈ្មោះ [redacted] **សុខឃីម**

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ទឹម** ភេទស្រី អាយុ៤៦ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិបន្ទាយជ័យ ឃុំស្តី ស្រុកចំការលើ ខេត្តកំពង់ចាម ។

តាមពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៦-៩-២០០៤ របស់ឈ្មោះ [redacted] **សែ** ប្តឹងឧទ្ធរណ៍នឹងសាលក្រមលេខៈ ១០២(គ) ចុះថ្ងៃទី១៣-៩-២០០៤ របស់តុលាការខេត្តកំពង់ធំ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

## **ឯរឿងហេតុមានដូចតទៅ**

កាលពីថ្ងៃទី១៧-៧-២០០១ ក្រុមចោរមាន៧នាក់ មានអាវុធគ្រប់ដៃចំណាំមុខច្បាស់ តែមិនស្គាល់ឈ្មោះ បានទៅប្លន់ដែលខ្លួនបានដេកជិះចំការ នៅភូមិត្រពាំងឬស្សី ឃុំគីរធំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ បានប្លន់យកប្រាក់ពីខ្លួនអស់ចំនួន៤០ម៉ឺនរៀល ដោះយកក្រវិល និង នាឡិកា រួចវាភ្ជង់ខ្លួនចងបណ្តើរយកទៅបង្ខាំបយកប្រាក់១៥០០$ ខ្លួនរកបានតែ៥០០$ តែមិនបានយកឱ្យពួកវាទេ ព្រោះសមត្ថកិច្ចបានជួយអន្តរាគមន៍ទាន់ពេល ពួកវាចាប់ខ្លួនទៅលឺវាហៅ **អាម៉ៅ, អាតឿ, អាឃក្ស, អាណារ៉េត, អាញាញ់, ច័ន្ទ សែ, អាគម** ហៅ [redacted] **សន** និង **អាគ្រឹម** ។ អ្នកនាំទៅចាប់ជំរិតមានឈ្មោះ [redacted] **ឈិន**, [redacted] **ឆាន** ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សែ** ឆ្លើយថាៈ កាលពីថ្ងៃទី១៧-៧-២០០១ ខ្លួនបាននៅដេកភូមិស្វាកែត ពុំបានទៅណាមកណាទេ ជាប់រវល់ធ្វើស្រែ មិនដឹងជនទុច្ចរិតទៅចាប់ជំរិតយកប្រាក់នៅតំបន់ត្រពាំងឬស្សីផង ហើយថ្ងៃក្រោយមកទៀត ខ្លួនមិនបានដឹងថាមានចោរចាប់ជំរិតទារប្រាក់នៅតំបន់នោះទេ ។ ចំពោះឈ្មោះដែលជាប់ចោទទាំងអស់នោះ ខ្លួនស្គាល់ឈ្មោះ [redacted] **សន**, [redacted] **អ៊ុខណារ៉េត** ហៅ **ញឹង** នឹងឈ្មោះ [redacted] **នឿន** ព្រោះនៅភូមិជាមួយគ្នា ឯ២នាក់ទៀតឈ្មោះ [redacted] **ឈិន**. [redacted] **ឆាន** ខ្លួនមិនស្គាល់គេទេ មិនដឹងនៅភូមិណាទេ ហើយមិនដឹងអ្នកទាំងអស់នោះគេរកស៊ីអ្វីដែរ ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សន** នឹងឈ្មោះ [redacted] **ណារ៉េត** ហៅ **ញឹង** ឆ្លើយប្រហាក់ប្រហែលគ្នាថាៈ ខ្លួនមិនបានដឹងក្រុមចោរចាប់ជំរិតបង្ខាំបយកប្រាក់ ឯភូមិត្រពាំងឬស្សីនោះទេ ខ្លួនមិនបាននៅជិតអនុវិទ្យាល័យ ហ៊ុន សែន នោះទេ កាលពីថ្ងៃទី២២-៧-២០០១ វេលាម៉ោង១០ព្រឹក ខ្លួនបានចូលទៅចំការពោត ឈ្មោះ រ៉ា បានស្រែកសួររកម្ចាស់ពោតមិនឃើញ បានកាច់ពោតវិចក្រម៉ា បានដើរចេញ ឃើញគោស៊ីសំណាប ខ្លួនបានដេញគោសួររកម្ចាស់គោ បានជួបឈ្មោះ **ឌាត** គាត់ថាមិនដឹង ដើរចូលចំការពោតម្តងទៀត សួររកម្ចាស់គោ តែមិនឃើញ ដើរបាន៣០មជួបនគរបាលម្នាក់ ខ្លួនដើរចេញពីផ្លូវធំ ខ្លួនបានជួបឈ្មោះ [redacted] **យ៉ាត** គាត់សួរ ក្មួយឯងរកអី ខ្លួនប្រាប់ពីរឿង/.

គោស៊ីសំណាប ខ្លួនបានមកផ្ទះប្រាប់ម្តាយថា គោស៊ីសំណាប គាត់បានទៅមើលសំណាប កាន់កាំបិត១ទៅជាមួយចៅគាត់ ។ សំណូមពរ សូមតុលាការជួយរកយុត្តិធម៌ឱ្យផង ខ្លួនមិនបានចាប់ជំរិត និង ប្លន់ទេ ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ឈិន** ឆ្លើយថាៈ ខ្លួនមានដីចំការនៅតំបន់ត្រពាំងឫស្សី ឃុំគគីរធំ ជិតដីចំការរបស់ដើមបណ្តឹងដែរ ឯទីលំនៅសព្វថ្ងៃនៅភូមិជាមួយគ្នា ខ្លួនជាមេក្រុមទី៦ ខ្លួននឹងដើមបណ្តឹងមិនដែលមានទំនាស់គ្នាទេ តែមានទំនាស់ និង កូនខ្លួនខ្លះៗដែរ ថ្ងៃទី១៧-៧-២០០១ ខ្លួននៅខ្ទមចំការមានចំងាយ៤០០ម ពីខ្ទមដើមបណ្តឹង ខ្លួននៅសំរាកយប់នោះរហូតដល់ភ្លឺ ពេលភ្លឺបានដឹងដោយឈ្មោះ **ខេង** និយាយប្រាប់ថា យប់មិញឈ្មោះ [redacted] **ទឹម** ចោរប្លន់បានចាប់គាត់ៗស្រែកឱ្យគេជួយ រួចខ្លួនមកផ្ទះភូមិទុកពីរយកររទេះ មិនបានសួរសុខទុក្ខឈ្មោះ [redacted] **ទឹម** ទេ ។ កាលពីថ្ងៃទី១៧-៧-២០០១ ខ្លួនដើរកាត់ចំការក្បែររោ[redacted] **ទឹម** ឆ្ពោះទៅរោងឈ្មោះ [redacted] **សុខ** ដើម្បីទៅប្រាប់ឱ្យយកកម្មករទៅដាំសណ្តែក ក៏យប់នោះកើតហេតុតែម្តង ។ ខ្លួនមិនបាននាំចោរទៅចាប់ជំរិតឈ្មោះ [redacted] **ទឹម** ទេ មិនបានស្គាល់ចោរទាំងនោះទេ ហើយមិនបានដឹងថ[redacted] **ទឹម** ត្រូវចោរចាប់ជំរិតដែរ ពេលព្រឹកទើបខ្លួនបានដឹង ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ឆាន** ឆ្លើយថាៈ ខ្លួនមិនបានប្រព្រឹត្តបទចោទនេះទេ ខ្លួនមានដីចំការនៅតំបន់ត្រពាំងឫស្សីនោះដែរ តែខ្លួនលឺតែកុងត្រាក់ទ័រនិយាយប្រាប់ថា មានក្រុមចោរចាប់ជំរិតទារលុយអ្នកចំការនៅតំបន់ត្រពាំងឫស្សី ហើយអ្នករងគ្រោះឮថាយកមកលែងនៅអនុវិទ្យាល័យក្រវ៉ៃ ឯចោរចាប់ជំរិតយកលុយនោះចំនួនប៉ុន្មាននោះពុំដឹងទេ ចំពោះឈ្មោះ [redacted] **សន** ខ្លួនឃើញស៊ីឈ្នួលជរះចំការ ខ្លួនមិនដែលឃើញស្ពាយកាំភ្លើងទេ ឈ្មោះ [redacted] **សៃ** ហៅ **ញឿ** មានផ្ទះនៅភូមិស្វាកែត ខ្លួនបានស្គាល់ ខ្លួនមិនដឹងវាមានកាំភ្លើង ឬអត់ ហើយខានជួបវាជិតមួយឆ្នាំមកហើយ ចំពោះរូបខ្លួនពុំបានលក់អាវុធ ឈ្មោះ [redacted] **សន** ខ្លួនស្គាល់ដែរ ។ សូមតុលាការជួយរកយុត្តិធម៌ឱ្យផង ។

-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ទឹម** ឆ្លើយថាៈ ខ្លួននឹងប្តីព្រមទាំងកូន មានទីលំនៅភូមិបន្ទាយជ័យ ឃុំស្ពឺ តែខ្លួនមានដីចំការនៅក្នុងតំបន់ត្រពាំងឫស្សី ស្ថិតនៅឃុំគគីរធំ ចំនួន៧ឆ្នាំមកហើយ បានសង់រោងរស់នៅ ពេលកើតហេតុជារដូវដាំសណ្តែកសៀង ខ្លួនបានជួលកម្មករជាច្រើននាក់មកដាំសណ្តែកសៀងនេះ បានមកស្នាក់នៅរោងខ្លួននេះ ចំការគេនៅជិតគ្នា ។ លុះដល់ថ្ងៃទី១៧-៧-២០០១ វេលាម៉ោង៨យប់ ពួកកម្មករបានដេកលក់អស់ហើយរោងខ្លួន ពួកកម្មករមាន៧នាក់ ចោរបានឡើងលើរោង២នាក់ មានកាំភ្លើងគ្រប់ដៃធុនអាកាបត់មួយដើម ឃើញពន្លឺពិលមានស្លៀកពាក់ទាហ៊ាន មានឈ្មោះ **អាតឿ** និង **អាម៉ៅ** វាវៃកម្មករនឹងកាំភ្លើង ដោះយកក្រវិល នាឡិកា ។ ឯ៥នាក់ទៀតមានកាំភ្លើងAK ស្ពាយបត់គ្រប់ដៃ មានខោអាវទាហ៊ានមួកទាហ៊ាន វាទៅយកប្រាក់ខ្លួនអស់៤០ម៉ឺនរៀល និងយកខោអាវចាប់ខ្លួនបណ្តើរទៅរោងម្តាយខ្លួនឈ្មោះ **មុំ** នឹងក្មួយស្រីឈ្មោះ [redacted] **ឃឹម** គំរាមយកប្រាក់៤តំឡឹង តែមិនខាន បានប្រាក់៣០ម៉ឺនរៀល និង យកកូនវិទ្យុតូចៗអស់២គ្រឿង រួចវានាំខ្លួនម្តាយ ក្មួយ បណ្តើរទៅតំបន់ត្រពាំងទន្សាយពេលព្រឹកវាដាក់ច្រវាក់ពេញមួយថ្ងៃ រួចបន្ទើរខ្លួនមកជិតរោងមានចំងាយ១៥គម បានមួយយប់ទារប្រាក់មួយម៉ឺនដុល្លាខ្លួនសុំវាចុះត្រឹម៣០០០ដុល្លា វាលែងម្តាយខ្លួនឱ្យទៅរកលុយ កន្លែងណាត់សាលាអនុវិទ្យាល័យ ហ៊ុន សែន កំណត់ថ្ងៃទី២០-៧-២០០១ ។ លុះថ្ងៃទី១៩-៧-២០០១ ពេលល្ងាចវានាំខ្លួននឹងក្មួយទៅខាងលិចរោងចក្រហ្គេត ចំនួន២យប់ ម្តាយខ្លួនបានសុំអង្វរ១ថ្ងៃទៀត ។ ថ្ងៃទី២១-៧-២០០១ ពួកវាបានលែងពួកខ្លួន ហើយបង្គាប់ឱ្យរកលុយ១៥០០$ បើមិនបាន

សំលាប់ចោល រកលុយបាន៥០០$ តែវាមិនហ៊ានមកទទួលទេ ដោយមានប៉ូលីស និង ទាហ៊ាន ជួយអន្តរាគមន៍ ។ ឈ្មោះ [redacted] **ឈិន** និងឈ្មោះ [redacted] **ឆាន** ជាបក្ខពួក ក្រុមចោរចាប់ជំរិតមាន៧នាក់ ដែលក្រុមវាហៅ **អាម៉ៅ**, **អាតឿ**, **អាយក្ស**, **អាលោកគ្រូ**, **អាញ៉ាញ់**, [redacted] សែ, **អាគម**, [redacted] **សន**, **អាក្រឹម** ។ ឈ្មោះ **ញឿង** ប្រពន្ធរបស់ឈ្មោះ [redacted] **សន** សមត្ថកិច្ចបានឃើញទូលបាយឱ្យចោរ ក្រោយមកវារើសយកច្រវាក់ដែលចោរដាក់ខ្លួន ។ សុំផ្តន្ទាទោសជនល្មើសតាមច្បាប់ ទាមទារយកប្រាក់វិញ៤០ម៉ឺនរៀល ទាមទារជម្ងឺចិត្ត១.៥០០.០០០រ០០ ។

-តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] **ឃីម** ឆ្លើយថា: កាលពីថ្ងៃទី១៧-៧-២០០១ វេលាម៉ោង៨ ពួចោរគំរាមនឹងព្ទស្នូរវៃទៅរោង អ៊ុំ [redacted] **ចឹម** កន្លះម៉ោងក្រោយមក វាមករោងយាយខ្លួន មានចោរឈ្មោះ **ម៉ៅ** និង ឈ្មោះ **យក្ស** មានកាំភ្លើងអាកាគ្រប់ដៃ ។ អាចោរឈ្មោះ **អាលោកគ្រូ** **អាម៉ៅ** សួររកម្ចាស់រោង ខ្លួនថា រត់បាត់ហើយ វាទាត់ខ្លួន៥ជើងចំឆ្អឹងជំនីទាំងសងខាង **អាម៉ៅ** មកសំរាតសារុងយាយខ្លួន ឈ្មោះ **ម៉ុំ** រកមាស៤តំឡឹងកន្លះ តែរកមិនឃើញ បានប្រាក់៣០ម៉ឺនរៀល វាចាប់បណ្តើរខ្លួន, យាយ, អ៊ុំ ទៅចំការត្រពាំងទន្សាយ ។ សុំផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ ។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] **ឈឹម** ឆ្លើយថា: កាលពីថ្ងៃទី១៧-៧-២០០១ វេលាម៉ោង៨កន្លះយប់ ខ្លួនដេកលក់នៅរោងចំការ ពួកចោរឡើងលើរោងមកដាក់ក្បាលខ្លួន មកឆក់ក្រវិលខ្លួន នាឡិកាដៃ វាទៅទាត់ប្អូនស្រីខ្លួន ចោរមានគ្នា៦ទៅ៧នាក់ ខ្លួនមិនស្គាល់ទេ ។ មុនកើតហេតុមួយថ្ងៃខ្លួនឃើញឈ្មោះ [redacted] **ឈិន** ដែលកន្ទួមកគាត់មានដៃជើង ធ្លាប់លួចរបស់អ៊ុំខ្លួន ម្តាយមីងខ្លួន ប៉ូលីសស្រាវជ្រាវរកឃើញសំរូលគ្នាចប់ ហើយដំបូងវាកាប់ដើមខ្នុរម្តាយ និង ឈ្មោះ **រឿន** បន្ទាប់មកលួចសណ្តែកសៀង វានេះគុំគាត់បាននាំចោរមកចាប់ជំរិតអ៊ុំខ្លួន៧មិនស្គាល់ចោរទេ ។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] **សារឿន** ឆ្លើយថា: កាលពីថ្ងៃទី១៧-៧-២០០១ វេលាម៉ោង៨យប់ ខ្លួននឹងប្រពន្ធព្រមទាំងកូនប្រុសសំរាកលើគ្រែ ក្នុងយ៉ាកឯដី ប្អូនថ្លៃខ្លួន និង កូនវា៣នាក់ និង កម្មករស្រី២នាក់ ក៏ដេកសំរាកលើរោង ឯកម្មករប្រុស១ដេកសំរាកក្រោយរោង ចងអង្រឹងចំនួន៤នាក់ ចោរឡើងលើរោងពួសួរប្រាវ ខ្លួនភ្ញាក់ ខ្លួនរត់ទៅពួនគុម្ពចេក មានចំងាយពីរោង១០ម ពួកចោរមានគ្នា៧នាក់ មានកាំភ្លើងគ្រប់ដៃ ពេលវាចេញអស់បាននាំប្រពន្ធខ្លួនឈ្មោះ [redacted] **ចឹម** ម្តាយក្មេក ក្មួយស្រី យកទៅបង្ខាប់យកលុយ ។ រដ្ឋអំណាចទៅជួយអន្តរាគមន៍ រំដោះប្រពន្ធបានមកវិញ ។ ខ្លួនសង្ស័យឈ្មោះ [redacted] **ឈិន** ព្រោះវាពីក្បាលល្ងាច បាននាំមនុស្សប្រុសម្នាក់ដើរកាត់ចំការខ្លួន និង ចំការម្តាយក្មេក ក៏ដើរទៅកើត ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ:១០២(គ) ចុះថ្ងៃទី១៣-៩-២០០៤ របស់តុលាការខេត្តកំពង់ធំ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១-ផ្តន្ទាទោសឈ្មោះ [redacted] **សែ** ភេទប្រុស អាយុ៣១ឆ្នាំ ដាក់ពន្ធនាគារ១៣ឆ្នាំ គិតតាំងពីផុតសាលក្រមលេខ:៤៤ ចុះថ្ងៃទី០៤-៤-២០០២ ។

-ឈ្មោះ [redacted] **ហ៊ន** ហៅ **ក្រឹម** ភេទប្រុស អាយុ៣០ឆ្នាំ ដាក់ពន្ធនាគារ១៣ឆ្នាំ គិតតាំងពីផុតសាលក្រមលេខ:១៩៥ ចុះថ្ងៃទី៣០-៦-២០០៣ ។

-ឈ្មោះ[redacted] **សន** ភេទប្រុស អាយុ៣៣ឆ្នាំ ដាក់ពន្ធនាគារ១២ឆ្នាំ គិតតាំងពីសាលក្រមអនុវត្តចូលជាស្ថាពរ ។

-ឈ្មោះ[redacted] **ឈិន** ភេទប្រុស អាយុ៥៣ឆ្នាំ

-ឈ្មោះ[redacted] **ឆាន** ភេទប្រុស អាយុ៣៧ឆ្នាំ

ដាក់ពន្ធនាគារម្នាក់១២ឆ្នាំ អ្នកទាំងពីរនេះគិតតាំងពីអនុវត្តសាលក្រមចូលស្ថាពរ ។ អ្នកទាំង៥នាក់ខាងលើចោទពីបទៈអំពើភេរវកម្ម និង អំពើប្លន់ ប្រព្រឹត្តនៅភូមិត្រពាំងឫស្សី ឃុំគគីរធំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី១៧-៧-២០០១ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា២ នៃច្បាប់ស្តីពីការផ្តន្ទាទោសអំពើភេរវកម្ម និង មាត្រា៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-ឱ្យឈ្មោះ[redacted]**សែ**, ឈ្មោះ[redacted] **សន**, ឈ្មោះ [redacted] **ឈិន**, ឈ្មោះ [redacted] **ឆាន**, ឈ្មោះ [redacted] **ហំន** ហៅ **គ្រឹម** រួមគ្នាជូសជុលសំណង៤០ម៉ឺនរៀល ជម្ងឺចិត្តមួយលានរៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **សុខ ទឹម** បណ្តឹងលើសពីនេះ ត្រូវលើកចោល បើឈ្មោះ [redacted] **សែ**, [redacted] **សន**, [redacted] **ឈិន**,[redacted] **ឆាន**, [redacted] **ហំន** ហៅ **គ្រឹម** មិនមានប្រាក់បង់ទេ បង្ខំរូបកាយដាក់គុកទារប្រាក់ធនទណ្ឌ ។

៣-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ **ខ័ន្ត សែ**, កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] **សន**, [redacted] **ឈិន**[redacted] **ឆាន**,[redacted] **ហំន** ហៅ **គ្រឹម**, និង ដើមបណ្តឹងរដ្ឋប្បវេណី ទុកសិទ្ធិប្តឹងទាស់, ឧទ្ធរណ៍ ក្នុងកំណត់ច្បាប់ ។

-បានឃើញរបាយការណ៍ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

-បានឃើញសេចក្តីសន្និដ្ឋាន ចុះថ្ងៃទី១៩-៥-២០០៥ របស់តំណាងអយ្យការសាលាឧទ្ធរណ៍ ។

## <u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ [redacted] **សែ** ឆ្លើយថាៈ ខ្លួនដឹងតុលាការចោទខ្លួនពីបទៈភេរវកម្ម ហើយផ្តន្ទាទោសដាក់ពន្ធនាគារ១៣ឆ្នាំ ។ ខ្លួនមិនសុខចិត្តប្តឹងឧទ្ធរណ៍ ព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ព្រោះថ្ងៃកើតហេតុ ខ្លួននៅផ្ទះ ខ្លួនមានសាក្សី នៅតុលាការខេត្តសាក្សីខ្លួនបានចូលឆ្លើយបំភ្លឺហើយ ពេលនៅផ្ទះខ្លួនមិនមានធ្វើអ្វីទេ ។ សាក្សីឈ្មោះ[redacted] **ខឹម** និង ឈ្មោះ[redacted] **ហ៊ឹម** ។ សមត្ថកិច្ចចាប់ខ្លួននៅផ្ទះ ខ្លួនសំណូមពរសុំឱ្យលើកពៃរងចោទប្រកាន់ដល់រូបខ្លួន ។

-ដើមបណ្តឹងឈ្មោះ[redacted] **ទឹម** ឆ្លើយថាៈ ខ្លួនស្គាល់ជនជាប់ចោទ [redacted] **សែ** នេះច្បាស់ គឺជាអ្នកប្លន់ជីវិតទារប្រាក់ខ្លួន ។ ថ្ងៃកើតហេតុពេលល្ងាច ខ្លួនកំពុងងូតទឹក ពេលនោះឈ្មោះ[redacted] **ឈិន** នាំចោរមកក្បែរហើយនិយាយថា នាងឯងមិនខ្លាចចោរចាប់ទេឬ ខ្លួនថា មិនខ្លាចទេ លុះយប់ឡើងពួកចោរក៏ចូលមកចាប់ខ្លួននៅពេលយប់ងងឹត លុះព្រឹកឡើងចោរនៅជុំគ្នាមិនបិតមុខទេ ។ ពីមុនមិនស្គាល់ពួកចោរទេ គឺស្គាល់តែឈ្មោះ [redacted] **ឈិន** ឯពួកចោរផ្សេងទៀតស្គាល់នៅពេលព្រឹក ។ ពួកចោរចាប់ខ្លួន៥ថ្ងៃ៥យប់ មានខ្លួន, [redacted] **ឃឹម** និង ម្តាយខ្លួន ។ សព្វថ្ងៃ[redacted] **ឃឹម** នៅប៉ោយប៉ែត ម្តាយខ្លួនស្លាប់ហើយ ឯឪពុកខ្លួនស្លាប់ពេលចោរចាប់ពួកខ្លួន ដោយគាំងបេះដូង ។ ពេលចាប់ ចោរទារ១ម៉ឺនដុល្លា ខ្លួនអង្វរនៅសល់៣ពាន់ដុល្លា តែខ្លួនទើបប្រគល់ឱ្យបាន១៥០០ដុល្លា គឺឱ្យឈ្មោះ **យក្ស** និង ឈ្មោះ **ម៉ៅ** ព្រោះ៕

ពីរនាក់នៅមើលពួកខ្លួនៗស្គាល់ឈ្មោះពួកចោរ ដោយវាហៅឈ្មោះគ្នាវា ពួកចោរស្លៀកពាក់ទាហាន មានកាំភ្លើងគ្រប់ដៃ ។ ពួកចោរចាប់ឪពុកមាខ្លួនបាន៣ថ្ងៃ ទើបមកចាប់ពួកខ្លួន ។ ខ្លួនសំណូមពរសុំឱ្យតម្កល់សាលក្រម ដដែល ។

-តំណាងមហាអយ្យការសន្និដ្ឋានថា: ឆ្លងតាមសវនាការនាពេលនេះឃើញថា ជនរងគ្រោះបានស្គាល់ជនជាប់ចោទយ៉ាងច្បាស់ គឺពិតជាឈ្មោះ [redacted] សៃ និង បក្ខពួកនេះហើយដែលបានប្លន់ជនរងគ្រោះ ចំពោះការឆ្លើយបដិសេធរបស់ជនជាប់ចោទឃើញថា គ្មានអ្វីជាសំអាងទេ ហេតុនេះសុំឱ្យតម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ១០២(គ) ចុះថ្ងៃទី ១៣-៩-២០០៤ របស់សាលាដំបូងខេត្តកំពង់ធំ ដដែល ។

-មេធាវីការពារជនជាប់ចោទសន្និដ្ឋានថា: ទាក់ទងរឿងនេះ ក្រោយសាកសួរឃើញថាមានសាក្សីឈ្មោះ **ឃីម** ថាស្គាល់ឈ្មោះ **ម៉ៅ** សាក្សីឈ្មោះ **ស៊ុំ** ថា គ្រាន់តែដឹងថា ថ្ងៃកើតហេតុឈ្មោះ [redacted] **ឈិន** ដើកាត់ចំការរបស់គាត់ ឈ្មោះ [redacted] **ឃឿន** គ្រាន់តែដឹងពីសកម្មភាពប្លន់ មិនបានឃើញផ្ទាល់ទេ ។ ជនជាប់ចោទមានគ្នាច្រើននាក់ តែបានឆ្លើយបដិសេធរហូត ។ ហេតុនេះសុំឱ្យលើកលែងចោទប្រកាន់ដល់កូនក្តីខ្លួន ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់ ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យគ្រប់ឯកសារ

-ក្រោយពីបានពិចារណាត្រឹមត្រូវហើយ

## សាលាឧទ្ធរណ៍

១-យល់ឃើញថា: ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៦-៩-២០០៤ របស់ឈ្មោះ [redacted] សៃ ធ្វើឡើងតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន យោងតាមបញ្ញត្តិមាត្រា១៧៨ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ និង មាត្រា៦០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា: រឿងក្តីនេះ គឺមានតែឈ្មោះ [redacted] សៃ ម្នាក់តែប៉ុណ្ណោះ ដែលបានប្តឹងឧទ្ធរណ៍ទៅនឹងសេចក្តីសម្រេចរបស់សាលាដំបូងខេត្តកំពង់ធំ ដូចនេះសាលាឧទ្ធរណ៍ លើកយកតែករណីឈ្មោះ [redacted] សៃ នេះមកពិចារណា តែប៉ុណ្ណោះ ។

៣-យល់ឃើញថា: ជនជាប់ចោទឈ្មោះ [redacted] សៃ បានបដិសេធថា ខ្លួនពុំបានប្រព្រឹត្តអំពើចាប់ជំរិតមនុស្សទារប្រាក់ ដូចការចោទប្រកាន់នោះទេ ប៉ុន្តែតាមការបំភ្លឺរបស់ជនរងគ្រោះឈ្មោះ [redacted] ទឹម និង [redacted] ឃីម បានបញ្ជាក់ថា ក្រុមជនល្មើសបានចាប់ពួកខ្លួនទៅបង្ខាំងទុកជាច្រើនថ្ងៃ ដើម្បីឱ្យបងប្អូនសាច់ញាតិយកប្រាក់ទៅលោះ ហើយក្នុងរយៈពេលដែលស្នាក់នៅជាមួយជនល្មើសក្នុងព្រៃនោះ គឺខ្លួនបានស្គាល់មុខនឹងឈ្មោះជនល្មើសច្បាស់ ហើយក្រោយពីសមត្ថកិច្ចចាប់បានជនល្មើសឈ្មោះ [redacted] សៃ នេះបានមកនោះ ជនរងគ្រោះបានចង្អុលបង្ហាញយ៉ាងច្បាស់ថា ឈ្មោះ [redacted] សៃ នេះ គឺជាសមាជិកម្នាក់ក្នុងចំណោមជនល្មើស ដែលចាប់ពួកខ្លួនជំរិតទារប្រាក់នេះ ។

៤-យល់ឃើញថាៈ តាមការចង្អុលបង្ហាញរបស់ជនរងគ្រោះ ជាដើមបណ្តឹងរដ្ឋប្បវេណី និង តាមការបំភ្លឺរបស់សាក្សីបានបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] សែ ពិតជាបានចូលរួមចាប់ជនរងគ្រោះ ជំរិតទារប្រាក់ប្រាកដមែន ។

៥-យល់ឃើញថាៈ មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] សែ ពីបទៈភេរវកម្ម ប្រព្រឹត្តនៅភូមិត្រពាំងឫស្សី ឃុំគគីរធំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី១៧-៧-២០០១ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា២ នៃច្បាប់ស្តីពីការផ្តន្ទាទោសអំពើភេរវកម្ម ។

៦-យល់ឃើញថាៈ រឿងក្តីនេះសាលាដំបូងខេត្តកំពង់ធំ បានធ្វើការអង្កេត និង លើកយកភស្តុតាងមកសំអាងជូនសព្វគ្រប់ហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនេះ ដូចនេះសាលាឧទ្ធរណ៍ ពុំចាំបាច់លើកយកសំអាងហេតុដដែលនេះ មកបញ្ជាក់ជាថ្មីទៀតទេ ។

៧-យល់ឃើញថាៈ ការសំរេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សែ របស់សាលាដំបូងខេត្តកំពង់ធំ ធ្វើឡើងមានលក្ខណៈត្រឹមត្រូវហើយ គប្បីតម្កល់ទុកជាបានការដដែល ។

## <u>ហេតុដូច្នេះវិនិច្ឆ័យសេចក្តី</u>

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៦-៩-២០០៤ របស់ឈ្មោះ [redacted] សែ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សេចក្តីសម្រេចផ្តន្ទាទោសលើឈ្មោះ [redacted] សែ ក្នុងចំណុចទី១នៃសេចក្តីសម្រេច របស់សាលក្រមព្រហ្មទណ្ឌលេខៈ១០២(គ) ចុះថ្ងៃទី១៣-៩-២០០៤ របស់សាលាដំបូងខេត្តកំពង់ធំ ទុកជាបានការដដែល ។

៣-សំរេចឃុំខ្លួនឈ្មោះ [redacted] សែ នេះជាបន្ត ។

៤-សាលដីកានេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សែ មេធាវីការពារ និង ដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងតវ៉ា តាមកំណត់ច្បាប់ ។៚

***សាលដីកានេះបានចូលជាស្ថាពរនិងមានអានុភាពអនុវត្តលើឈ្មោះ វិន្ត សែ ដែលបានប្តឹងឧទ្ធរណ៍ប៉ុណ្ណោះ ។***

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និង កងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឱ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។៚**

ក្រឡាបញ្ជី

ហត្ថលេខា [redacted]

ចៅក្រមប្រឹក្សា

ហត្ថលេខា [redacted], [redacted]

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

ហត្ថលេខា [redacted]

បានឃើញ

**ប្រធានសាលាឧទ្ធរណ៍**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី 30 ខែ 5 ឆ្នាំ ២០១៤

**ក្រឡាបញ្ជី**

[redacted]